## ឧបសម្ព័ន្ធទី ១: បទពិសោធន៍ក្នុងការធ្វើការគ្រប់គ្រងការដាំដើមឈើ និង បទពិសោធន៍ពីបណ្តាប្រទេសមួយចំនួន

## ១. ការដាំដើមឈើដោយរដ្ឋាភិបាល/កម្មវិធីថ្នាក់ជាតិ

ជាប្រពៃណី តួនាទីរបស់វិស័យព្រៃឈើ អ្នកនយោបាយមួយចំនួន បានយល់ស្របគ្នាថាការកាន់កាប់ និងគ្រប់គ្រងធនធានព្រៃឈើដោយរដ្ឋាភិបាលមិនមែនជាដំណោះស្រាយដ៏ល្អនោះទេ។ គឺជាការងារមួយដែលទាមទារនូវចំណាយខ្ពស់ ជួនកាលពឹងផ្អែកលើប្រាក់កំចីពីខាងក្រៅ ហើយលើកទឹកចិត្តតិចតួចដល់ការចូលរួមពីសាធារណៈជនជាទូទៅ និងចុងបញ្ចប់បរាជ័យក្នុងការដោះស្រាយនូវឫសគល់នៃការបាត់បង់ព្រៃឈើ និង ការធ្វើឱ្យព្រៃឈើរេចរិល។

គេពិនិត្យឃើញមានការកើនឡើងជាបន្តបន្ទាប់នូវការបង្វែរតួនាទីរបស់រដ្ឋាភិបាលពីការងារដាំដើមឈើ ទៅជាការអភិរក្សរយៈពេលវែង និង ការថែទាំនូវមុខងារផ្តល់សេវាកម្មខាងបរិស្ថានរបស់ព្រៃឈើ (ការពារទីជំរាល អភិរក្សធនធានសេនេទិកព្រៃឈើ) ដែលបំពេញតំរូវការរបស់សហគមន៍នានាដែលពឹងពាក់លើព្រៃឈើ និង ចូលរួមវិភាគទានយ៉ាងសំខាន់ដល់ការកត់បន្ថយភាពក្រីក្រ (តាមរយៈការបេះផ្លែឈើ ចំណីសត្វ រុក្ខជាតិឱសថ អុស/ធ្យូង និងអនុផលព្រៃឈើជាច្រើនប្រភេទទៀត) ហើយលើសពីនោះ គាំទ្រដល់ផ្នែកឯកជនឱ្យចូលរួមក្នុងការបង្កើតចំការឈើនៅលើដីដែលមិនមែនព្រៃឈើ។

### ប្រទេសថៃ

ការស្តារទីជំរាលដែលមានទំហំធំធេងនៅខេត្តឈៀងរ៉ៃ ត្រូវបានចាប់ផ្តើមនៅដើមទសវត្សទី ៩០ ដោយនាយកដ្ឋានភូមិន្ទព្រៃឈើ ដោយហេតុថាមានការបាត់បង់គំរបព្រៃនិងដីជាតិដីតាមរយៈប្រពៃណីនៃការប្រើប្រាស់ជាច្រកចេញចូលទៅកាន់ប្រទេសភូមានិងប្រទេសចិន។ នៅក្នុងភូមិមួយ**ដីកសិកម្មត្រូវបានគេដកហូតដោយមិនមានចេញសោហ៊ុយសងការខូចខាត ឬ ពិភាក្សាពិគ្រោះយោបល់ជាមួយកសិករម្ចាស់ដី** ហើយដីដែលដកហូតត្រូវបានប្រើប្រាស់សំរាប់ដាំដើមស្រល់ ដែលបង្ករមាន**ផលប៉ះពាល់ជាអវិជ្ជមានដល់ជីវចំរុះនៅស្រទាប់ព្រៃខាងក្រោម** ហើយចំការឈើនេះមិនអាចប្រើប្រាស់ជាទីធ្លាចិញ្ចឹមគោ (លែងគោឱ្យដើរស៊ី) ជាលក្ខណៈប្រពៃណីទៀតទេ។ នៅភូមិមួយទៀត អង្គការ ក្រៅរដ្ឋាភិបាលថ្នាក់មូលដ្ឋាន បានចរចារឱ្យមានកិច្ចសហការគ្រប់គ្រងរវាងអ្នកភូមិនិងនាយកដ្ឋានភូមិន្ទព្រៃឈើ។ អ្នកភូមិត្រូវបានគេជួលឱ្យដាំឈើនិងមើល

ផ្ទៃទាំចំការឈើដាំ ក៏ប៉ុន្តែនៅចុងបញ្ចប់នៃគំរោងដាំឈើ **អ្នកភូមិបានបាត់បង់ប្រាក់ចំណូល ហើយគេលែងអនុញ្ញាតឱ្យចូលទៅក្នុងព្រៃជាបន្តទៅទៀត** (Neef and Schwarzmeir, 2001) ។

**ប្រទេសវៀតណាម:**

- o កម្មវិធីដាំឈើ ៥ លាន ហិកតាក្នុងគោលដៅបង្កើតព្រៃការពារ ២ លាន ហិកតា និងព្រៃផ្តល់ផល ៣ លាន ហិកតាចាប់ពីឆ្នាំ ១៩៩៨-២០១០ ដោយផ្តោតជាសំខាន់លើតំបន់ភ្នំរេចរិល (ភ្នំត្រងោល) ។ កម្មវិធីដាំឈើនេះមាន លក្ខណៈជាការបញ្ជារពីលើចុះក្រោម ប្រកបដោយមហិច្ឆតា និង មានតំលៃថ្លៃកប់ពពក ។ គេហាក់ដូចជា**មានការពិចារណាតិចតួចប៉ុណ្ណោះ ថាតើការដាំឈើនោះសំរាប់អ្នកណា និងដាំធ្វើអ្វី** ហើយការអនុវត្តន៍កម្មវិធីនេះបង្កើតឱ្យមាន**សម្ពាធទៅលើប្រពៃណីនៃការប្រើប្រាស់ដី** ដែលធ្លាប់មាននៅក្នុងតំបន់ដែលត្រូវដាំឈើ ។ ក្រោយមកគេហាក់ដូចជា បន្ថយផ្ទៃដីមកនៅត្រឹមតែ៣លាន ហិកតាវិញ ដើម្បីឱ្យស្របទៅនឹងផ្ទៃដីដែលត្រូវស្តារឡើងវិញ ហើយស្របទៅនឹងផែនការអភិវឌ្ឍន៍នាពេលបច្ចុប្បន្ន (Lang, undated) ។
- o នៅក្នុងឧទ្យានជាតិបាវី ផ្ទៃដីព្រៃឈើត្រូវបានគេបង្វែរទៅឱ្យសហគមន៍និងគ្រួសារដែលគ្មានដីធ្លី ប៉ុន្តែពួកគេមិនត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការនៃផែនការគ្រប់គ្រងឧទ្យានជាតិទេ ។ អ្នកគ្រប់គ្រងឧទ្យានជាតិបាន**ជ្រើសរើស ប្រភេទឈើមិនបានសមស្រប**សំរាប់កម្មវិធីដាំដើមឈើ ដោយប្រើប្រាស់ភាគច្រើនជាប្រេងខ្យល់និងអាកាស្យា**ដែលធ្វើឱ្យថយចុះនូវជីវចំរុះ និង បង្ករអតុល្យភាពបរិស្ថានតាមរយៈការធ្លាក់ចុះនូវប្រភពទឹកនៅក្រោមដី និង ធ្វើឱ្យថយចុះនូវគុណភាពដី** ។ លើសពីនោះ**ដើមឈើដែលបានដាំមិនបាន ផ្តល់ផលដែលប្រជាជនត្រូវការសំរាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃរបស់ពួកគេទេ** (Neef and Schwarzmeir, 2001) ។

**ប្រទេសចិន:**

កម្មវិធីអភិវឌ្ឍន៍ខ្សែក្រវ៉ាត់ការពារនៅតំបន់ភាគខាងជើងទាំងបី បានចាប់ផ្តើមនៅឆ្នាំ ១៩៧៨ ក្នុងគោលដៅបង្កើតចំការឈើទំហំ ៣៥ លានហិកតា រហូតដល់ឆ្នាំ ២០៥០ ។ កម្មវិធីនេះបង្កើតឡើងក្នុងគោលដៅការពារបរិស្ថាន ហើយនៅក្នុងជំហានទីមួយគឺដើម្បីគ្រប់គ្រងដំណើរវិវឌ្ឍន៍ទៅកាន់ភាពរហោស្ថាននៅក្នុងតំបន់ ។ ក៏ប៉ុន្តែដំណើរវិវឌ្ឍន៍ទៅកាន់ភាពរហោស្ថាន បានវិវឌ្ឍន៍ក្នុងល្បឿនមួយលឿនជាងមុនទៅវិញ នេះដោយហេតុថា **ឬសគល់នៃបញ្ហាមិនត្រូវបានដោះស្រាយ ។ វិស័យព្រៃឈើនៃប្រទេសចិននៅតែមិនអាច**

បំពេញសេចក្តីត្រូវការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ឬ ក៏ធានានូវការអភិរក្សនៃសេវាកម្មខាងបរិស្ថាន ជាពិសេស ចាប់តាំងពីការធ្វើអាជីវកម្មឈើត្រូវបានបិទបន្ទាប់ពីមាន ទឹកជំនន់ដ៏ធ្ងន់ធ្ងរនៅឆ្នាំ ១៩៩៨ (Shi Yuanchun, undated) ។

## ២. ការដាំដើមឈើដោយផ្នែកឯកជន

ការចូលរួមរបស់ផ្នែកឯកជនមានការកើនឡើងជាបនបន្ទាប់ រួមទាំងសហគ្រាសធុនតូច ក្រុមហ៊ុនធំៗ (ជួលដីរដ្ឋ) គ្រួសារ(ដីឯកជន) និង ភាពជាដៃគូរ (ដែលអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើកិច្ចសហការជាមួយនឹងអ្នកកាន់កាប់ដីឯកជន) ។ ការងារនេះត្រូវបានគាំទ្រដោយការលើកទឹកចិត្តផ្អែកលើទីផ្សារ (ប្រាក់ឧបត្ថម្ភធន ប្រាក់កំចីដែលមានការ ប្រាក់ទាប ការលើកលែងពន្ធ) ការផ្សព្វផ្សាយអំពីផលប្រយោជន៍នៃអនុផលព្រៃឈើ និងការចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពឈើជាដើម ។ ការឆ្លុះបញ្ចាំងអំពីតួនាទីដែលបានផ្លាស់ប្តូរនេះគឺថាអាជ្ញាធរព្រៃឈើ ត្រូវបានកែសំរួល រចនាសម្ព័ន្ធ ។

## ២.១ ការជួលដីរដ្ឋ

ឧស្សាហកម្មដាំដើមឈើហាក់ដូចជាមានទំនោរក្នុងការប្រើប្រាស់ប្រភេទឈើដែលដុះលូតលាស់លឿននាំចូលពីបរទេស ដែលនេះជាហេតុនាំឱ្យគេកាប់ឆ្ការដីព្រៃដែលមានស្រាប់ដើម្បីដាំដើមឈើ ។ ទីតាំងដែលត្រូវបង្កើតចំការឈើដាំ ត្រូវបានប្រគល់ឱ្យនៅក្នុងតំបន់ដែលចាត់ទុកថាមិនមានការកាន់កាប់ ហេតុការណ៍នេះជារឿយៗនាំឱ្យបាត់បង់ឱកាស ក្នុងការចូលរុករកផលព្រៃឈើពីអ្នកដែលរស់នៅពឹងពាក់នឹងព្រៃឈើជាច្រើនជំនាន់មកហើយ ។

នៅពេលដែលតំរូវការផលិតផលឈើទាំងសំរាប់ការនាំចេញនិងសំរាប់ប្រើប្រាស់ក្នុងស្រុកមានការកើនឡើងឥតឈប់ឈរ គេសង្កេតឃើញមានក្រុមហ៊ុនធំៗចំនួន ១០ ផលិតនូវផលិតផលឈើប្រមាណ ៤០% នៃតំរូវការរបស់ពិភពលោក ហើយក្រុមហ៊ុនធំៗចំនួន ៥០ កាន់កាប់ផ្ទៃដីព្រៃឈើប្រមាណ ១៤០ លានហិកតា តាមរយៈការកាន់កាប់និងជួលដី (Mayers and Vermeulen, 2002) ។ ក៏ប៉ុន្តែនៅពេលដែលក្រុមហ៊ុនទាំងនេះកាន់តែរីកដុះដាលធំឡើងៗ ការពឹងផ្អែកលើផលិតផលតែមួយមុខ ឬពីរបីប្រភេទរបស់ក្រុមហ៊ុនទាំងនេះ ត្រូវប្រឈមមុខនឹងការផ្លាស់ប្តូរនៃតំរូវការរបស់អតិថិជន ។

ក្រុមហ៊ុនខ្លះ បន្តវិនិយោគនៅក្នុងតំបន់ទាំឡាយណាដែលអាចរកប្រាក់ចំណេញពីការចំណាយទាបប៉ុន្តែទទួលបានផលខ្ពស់ ហើយមានឥទ្ធិពលគ្រប់គ្រាន់លើការរៀបចំនយោបាយអនុគ្រោះ និងចៀសវាងនូវការគោរពតាមបណ្តាលិខិតបទដ្ឋានច្បាប់ដែលមានជាធរមាន ។ ក្រុមហ៊ុនខ្លះទៀតចាប់ផ្តើមឆ្លើយតបចំពោះសម្ពាធនៃ ការចូលរួមទទួលខុសត្រូវលើបញ្ហាសង្គមដើម្បីធ្វើឱ្យកាន់តែប្រសើរនូវទំនាក់ទំនងរបស់គេជាមួយនឹងបណ្តាអ្នកពាក់ព័ន្ធនានា (Mayers

and Vermeulen, 2002)ដែលជាលទ្ធផលនាំឱ្យមានភាពជាដៃគូរជាមួយនឹងសហគមន៍ និងអ្នកកាន់កាប់បីតូចតាច និង ទទួលការគាំទ្រពីរដ្ឋាភិបាលនិង បណ្តាអ្នកពាក់ព័ន្ធទីបីផ្សេងទៀតដូចជា NGOs ធនាគារ និងអាជ្ញាធរដែលចេញវិញ្ញាបនប័ត្រ។ ក្នុងនិន្នាការនាពេលបច្ចុប្បន្ននេះ វាហាក់ដូចជាមានការពិបាកក្នុងការវាយតំលៃថាតើ ការវិនិយោគរបស់ពួកគេអាចទទួលបានជោគជ័យឬមួយយ៉ាងណា។

**ប្រទេសថៃ**

ការដាំឈើសំរាប់បំរើគោលបំណងឧស្សាហកម្មត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំង ក្នុងការស្តារព្រៃរេចរិលនៅក្នុងដែនព្រៃបំរុងទុកនានា ក្នុងគោលបំណងបំពេញតំរូវការឧស្សាហកម្មកែច្នៃឈើ ការប្រើប្រាស់សំរាប់ជីវភាពប្រចាំថ្ងៃ និង អុសដុត។ **ពពួកអ្នកវិនិយោគទុនបានទទួលអត្ថប្រយោជន៍ជាច្រើនពីការជួលដីដែលមានរយៈពេលវែងនិងមានតំលៃថោកសំរាប់ដាំប្រភេទឈើឧស្សាហកម្ម** ដូចជាប្រេងខ្យល់ សំរាប់ផ្គត់ផ្គង់ដល់ឧស្សាហកម្មក្រដាស **ដែលនៅក្នុងករណីខ្លះដំណុះព្រៃសារឡើងវិញដោយធម្មជាតិត្រូវបានគេកាប់ឆ្ការ**។ ការវិនិយោគផ្តោតការយកចិត្តទុកដាក់លើការដាំឈើលើដីត្រងោល**ដោយពុំចាប់អារម្មណ៍ដល់សហគមន៍មូលដ្ឋាន**ដែលក្នុងករណីជាច្រើនបានកាន់កាប់ដីនោះ រាប់ជំនាន់មនុស្សមកហើយៗត្រូវបានគាំទ្រដោយគោលនយោបាយរបស់រដ្ឋាភិបាលមុន (Neef and Schwarzmeir, 2001)។

## ២.២ ដីឯកជន/ការដាំឈើនៅលើដីឯកជន

ការដាំឈើជាលក្ខណៈឯកជនឆ្លុះបញ្ចាំងពីនិន្នាការនៃនយោបាយផ្លាស់ប្តូរនៅក្នុងវិស័យព្រៃឈើ ហើយមានកាកើនឡើងនូវប្រជាប្រិយភាពតាមរយៈការទទួលស្គាល់ថា នាពេលអនាគតការផ្គត់ផ្គង់ឈើមូលនិងផលិតផលឈើផ្សេងៗទៀតមានប្រភពមកពីក្រៅដំណុះព្រៃធម្មជាតិ។ ឧទាហរណ៏នានាដែលបង្ហាញជូនខាងក្រោមបានបញ្ជាក់យ៉ាងច្បាស់ថា **នៅក្នុងអតីតកាល ការលើកទឹកចិត្តដោយផ្តល់ហិរញ្ញវត្ថុ បានផ្តល់ផលប្រយោជន៍សំរាប់តែអ្នកកាន់កាប់ដីធំៗតែប៉ុណ្ណោះ ហើយការគាំទ្រផ្សេងៗទៀតហាក់ដូចជាពុំមានប្រសិទ្ធិភាពទាល់តែសោះ**។

**ក្នុងនាមជាយុទ្ធសាស្ត្រមួយនៃកម្មវិធីដាំដើមឈើ ការដាំឈើជាលក្ខណៈឯកជនមាន លក្ខណៈនិរន្តរភាពមានប្រសិទ្ធិភាព និងជំរុញឱ្យមានសហគ្រិនភាពនៅឯមូលដ្ឋាន**។ ក៏ប៉ុន្តែគេសង្កេតឃើញមានការកើនឡើងនូវឧបសគ្គនានា ដូចជានៅក្នុងតំបន់ដែលអ្នកស្រុកមានការកាន់កាប់ដីតូចៗនោះនាំឱ្យថ្លៃដើមផលិតកម្មខ្ពស់ ការខ្វះខាតនូវសេវាកម្មផ្តល់ប្រាក់កំចី និង ភាពនៅឆ្ងាយពីទីផ្សារជាដើម ក៏ប៉ុន្តែឧបសគ្គទាំងនេះអាចត្រូវបានកាត់បន្ថយតាមរយៈគោលនយោបាយលើកទឹកចិត្តរបស់រដ្ឋាភិបាល ការផ្តល់ឱ្យនូវការលើកទឹកចិត្តនិងសេវាកម្មគាំទ្រនានា និង ការបង្កើត

ភាពជាដៃគូរវាងអ្នកកាន់កាប់ដីតូចតាច រដ្ឋាភិបាល និងផ្នែកឯកជន (Pasicolan, 2003)។

## ប្រទេសកូស្តារីកា

ចាប់តាំងពីទសវត្សឆ្នាំទី៧0 រហូតដល់ ទសវត្សឆ្នាំទី៩0 **ការលើកទឹកចិត្តដោយការផ្តល់ហិរញ្ញវត្ថុ ដល់កម្មវិធីដាំដើមឈើ បានក្លាយជាគោលនយោបាយព្រៃឈើដ៏សំខាន់ក្នុងការទាក់ទាញឱ្យមានការវិនិយោគក្នុងការដាំដើមឈើ។ មានតែម្ចាស់ឧស្សាហកម្មព្រៃឈើ និង ពួកម្ចាស់ដីធំៗប៉ុណ្ណោះដែលទទួលផលប្រយោជន៏ពីការលើកទឹកចិត្តនេះ ចំណែកម្ចាស់ដីតូចតាចបែរជាខាតបង់ទៅវិញ។** ក៏ប៉ុន្តែហេតុការនេះបានជំរុញឱ្យមានការបង្កើតសភានៃអ្នកកាន់កាប់ដី ព្រៃឈើតូចតាចថ្នាក់ជាតិមួយនៅឆ្នាំ១៩៩១។ លទ្ធផលមួយដែលគេសំរេចបានជោគជ័យ គឺការផ្លាស់ប្តូរប្រព័ន្ធនៃការលើកទឹកចិត្តដោយការផ្តល់ហិរញ្ញវត្ថុទៅជាការប្រគល់ឱ្យនូវការកាន់កាប់ក្បាលដីតូចៗ។ វិស័យព្រៃឈើនៃអ្នកកាន់កាប់ដីព្រៃឈើតូចតាចបានសំរេចជោគជ័យខាងផ្នែកសេដ្ឋកិច្ច ក៏ប៉ុន្តែការវិនិយោគតូចតាចលើឧស្សាហកម្ម អារឈើ កែច្នៃឈើ នៅមានកំរិតនៅឡើយ (Mayers and Bass, 1999)។

## ប្រទេសស្កុតឡែន

**ការបង្កើនពន្ធដារដល់ផ្នែកឯកជន**នៅដើមទសវត្សទី ៨0 បានទាក់ទាញអ្នកបង់ពន្ធធំៗឱ្យងាកមកវិនិយោគនៅក្នុងវិស័យព្រៃឈើវិញ (ដែលត្រូវបង់ពន្ធតិចជាង)តាមរយៈការដាំឈើនៅតំបន់ខ្ពង់រាប **ដែលផ្តល់ផលប្រយោជន៏ជាសំខាន់ដល់បណ្តាអ្នកកាន់កាប់ដីធំៗ។** ហេតុការណ៏នេះបាននាំឱ្យមានការផ្លាស់ប្តូរទំលាប់នៃការកាន់កាប់ដីដោយ**កសិករម្ចាស់ដីតូចតាចបានក្លាយទៅជាអ្នករងគ្រោះ** ហើយរារាំងការរីកដុះដាលនៃសេដ្ឋកិច្ចនៅជនបទនិងលទ្ធភាពនៃការគ្រប់គ្រងដីធ្លី។ ការបង្កើតឡើងនូវរដ្ឋសភាប្រទេសស្កុតឡែន នៅឆ្នាំ ១៩៩៩ បាននាំឱ្យមានកំណែទំរង់លើវិស័យផ្សេងៗ ដែលជាលទ្ធផលបង្កលទ្ធភាពឱ្យសហគមន៏មូលដ្ឋានទាមទារបាននូវសិទ្ធិកាន់កាប់និងគ្រប់គ្រងដីព្រៃឈើ (Mayers and Bass, 1999)។

## ប្រទេសវៀតណាម

នៅដីទំនាបព្រៃកក់នៃតំបន់ដីសណ្តរទន្លេមេគង្គ ការផ្លាស់ប្តូរគោលនយោបាយបាននាំទៅដល់ការបំផ្លាញ និងការស្តារឡើងវិញនូវដំណុះព្រៃស្មាច់ដោយធម្មជាតិ។ ចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំទី ៩0មក **ការទិញលក់ដីបានផ្តល់ឱកាសដល់កសិករអ្នកមានធនធាន ប្រមូលទិញបានដីធំៗ** ហើយពួកគេលៃទុកផ្នែកខ្លះសំរាប់ដាំឈើ ដែលសកម្មភាពនេះស្របគ្នាជាមួយនឹងសកម្មភាពរបស់សហគ្រាសដាំឈើរបស់រដ្ឋ និងរួមចំណែកក្នុងការស្តារធនធានព្រៃឈើឡើងវិញ។ ដោយឡែក កសិករតូចតាចដែលបានលក់ដីរបស់ខ្លួន បានក្លាយជា

អ្នកគ្មានដី ហើយអ្នកដទៃទៀតដែលគ្មានលទ្ធភាពដាំដើមឈើ បានទទួលរងគ្រោះពីការខាតបង់ទិន្នផលស្រូវរបស់ខ្លួនដោយសត្វកកេរ ដែលរស់នៅក្នុងព្រៃហើយបានចូលមកទន្រ្ទានទីវាលស្រែ នៅរដូវច្រូតកាត់ (Neef and Schwarzmeir, 2001) ។

**ប្រទេសប៉ាគីស្ថាន**

ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលបានចែកចាយកូនឈើដល់កសិករ ប៉ុន្តែកិច្ចការនេះទទួលបានជោគជ័យតិចតួចណាស់ ដោយហេតុថាកិច្ចការនេះមិនបានបំពេញនូវអ្វីដែលកសិករត្រូវការពិតប្រាកដ ។ ក៏ប៉ុន្តែគេសង្កេតឃើញមាន **សកម្មភាពដាំដើមឈើបានលេចជារូបរាងឡើងនៅលើដីស្រែដែលធ្វើឡើងដោយកសិករខ្លួនឯងផ្ទាល់ដោយសារតំលៃឈើនៅលើទីផ្សារអំណោយផលល្អ** ។ គេបានប៉ាន់ប្រមាណថា ព្រៃឈើប្រភេទនេះផ្គត់ផ្គង់ប្រមាណ ៨០% នៃផលិតផលឈើ និង អុសដែលប្រទេសជាតិត្រូវការ ។ មានបញ្ហាខ្លះៗដែរ ដែលកសិករត្រូវប្រឈមមុខទាក់ទងនឹងមធ្យោបាយសំភារៈ និង ទីផ្សារដែលមិនត្រូវបានដោះស្រាយនៅក្នុងផែនការដាំឈើប្រចាំឆ្នាំ (Mayers and Bass, 1999) ។

**ប្រទេសឥណ្ឌា**

កម្មវិធីដាំដើមឈើនៅលើដីឯកជនដែលបានចាប់ផ្តើមឡើងនាទសវត្សទី៧០ និង ៨០ បានលើកទឹកចិត្តម្ចាស់កសិដ្ឋានឱ្យដាំឈើសំរាប់ធ្វើអុសនិងចំណីសត្វ ក្នុងន័យកាត់បន្ថយសំពាធទៅលើព្រៃធម្មជាតិ ។ កម្មវិធីនេះបានចាត់ទុកការដាំឈើមានសារសំខាន់សំរាប់ជីវភាពប្រចាំថ្ងៃរបស់កសិករ ក៏ប៉ុន្តែកសិករភាគច្រើនដាំដើមប្រេងខ្យល់សំរាប់ធ្វើជាសរសរនិងអុស លក់ឱ្យអ្នកទីក្រុងជាជាងបំពេញតំរូវការនៃអ្នកទីទាល់ក្រ ។ ហេតុការណ៍នេះបានបង្ហាញថា **កសិករភាគច្រើនអាចផ្គត់ផ្គង់វត្ថុធាតុដើមដែលខ្លួនត្រូវការប្រសិនបើមានការលើកទឹកចិត្តមួយដ៏សមស្រប** ក៏ប៉ុន្តែរដ្ឋាភិបាលមិនបានគិតគូរទុកជាមុននូវការកើនឡើងនូវតំរូវការ ហើយពុំមានលទ្ធភាពជួយកសិករក្នុងការស្វែងរកទីផ្សារ ដែលជាលទ្ធផល ការដួលរលំនៃទីផ្សារឈើបានរុញច្រានកសិករមួយចំនួនឱ្យទទួលបរាជ័យក្នុងមុខជំនួញនេះ (Mayers and Bass, 1999) ។

## ២.៣ ភាពជាដៃគូរវាងក្រុមហ៊ុនឯកជន និងអ្នកកាន់កាប់ដីតូចតាច

ទំនាក់ទំនងរវាងក្រុមហ៊ុនឯកជន និង សហគមន៍មូលដ្ឋាន អាចចាត់ទុកជា**ជំហានដ៏រឹងមាំមួយក្នុងការឈានទៅពង្រីងឱកាសនៃកិច្ចការជំនួញនិងជីវភាពប្រចាំថ្ងៃ** ។ ឱកាសទាំងនេះ បានផ្តល់ដល់ក្រុមហ៊ុននូវសុវត្ថិភាពក្នុងការកាន់កាប់ដី និង ស្វែងរកកំលាំងពលកម្ម ហើយធានានិរន្តរភាពក្នុងការផ្គត់ផ្គង់ឈើ ក្នុងពេលជាមួយគ្នានោះ សហគមន៍

ទទួលបាននូវឱកាសបំពេញការងារ បច្ចេកវិជ្ជាថ្មីៗ ហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មសង្គម ប្រាក់ចំណូលនិងការស្វែងរកបាននូវផលិតផលពីព្រៃឈើជាច្រើនប្រភេទ។

ទោះជាយ៉ាងណាក៏ដោយសេចក្តីរំពឹងអំពីភាពជាដៃគូរនៅមិនទាន់បានបង្ហាញឱ្យឃើញច្បាស់លាស់នៅឡើយ ដោយសារនេះគ្រាន់តែជាសកម្មភាពដែលបំពេញសេចក្តីត្រូវការនៃជីវភាពប្រចាំថ្ងៃ ហើយភាពជាដៃគូរនេះនៅមិនទាន់បានរំដោះសហគមន៍មូលដ្ឋានឱ្យរួចផុតពីភាពក្រីក្រ លើសពីនេះ អ្នកដែលក្រីក្រខ្លាំងនិងអ្នកដែលគ្មានដីជាកម្មសិទ្ធិមិនបានទទួលផលប្រយោជន៍ពីភាពជាដៃគូរនេះទេ។ ភាពជាដៃគូរ បានជួបប្រទះនឹងបញ្ហា ដោយសារភាពក្សត់ខ្សោយនៃកម្មសិទ្ធិរបស់សហគមន៍ សម្ពាធពីទីផ្សារអន្តរជាតិសំរាប់ការទាញផលប្រយោជន៍រយៈពេលខ្លី និង លទ្ធភាពនៃការជំរុញឱ្យមានប្រសិទ្ធិភាពសេដ្ឋកិច្ចពេញបន្ទុក។ បញ្ហាប្រឈមចំបងៗរួមមានតំលៃនៃកិច្ចប្រតិបត្តិការដែលត្រូវចំណាយដោយក្រុមហ៊ុនមានកំរិតខ្ពស់ក្នុងការធ្វើប្រតិបត្តិការជាមួយនឹងសមាជិក ឬ ក្រុមនៃសមាជិកសហគមន៍ដែលថិតនៅរាយប៉ាយមិនប្រមូលផ្តុំ និង ប្រសិទ្ធិភាពក្នុងការធ្វើសេចក្តីសំរេចចិត្តសំរាប់ក្រុមដោយសហគមន៍មូលដ្ឋាន (Mayers and Vermeulen, 2002)។

## ប្រទេសឥណ្ឌា

សកម្មភាពរបស់ក្រុមហ៊ុនឯកជននៅលើដីរបស់រដ្ឋមិនត្រូវបានគាំទ្រទេ ហើយផ្ទៃដីដែលក្រុមហ៊ុនអាចកាន់កាប់បាន មានកំរិត ដូច្នេះហើយពួកគេទិញវត្ថុធាតុដើមពីអ្នកកាន់កាប់ដីតូចតាច។ **ឥឡូវនេះបណ្តាក្រុមហ៊ុននានាបានបណ្តុះ និង ចែកចាយកូនឈើដែលបណ្តុះពីក្លូន ហើយទិញមកវិញនូវវត្ថុធាតុដើមឈើក្នុងតម្លៃទីផ្សារសេរីដែលអនុញ្ញាតឱ្យអ្នកកាន់កាប់ដីតូចតាចទទួលផលចំណេញតាមរយៈការប្រកួតប្រជែងនេះ** (Mayers and vermuelen, 2002)។

## ប្រទេសអាហ្វ្រិកខាងត្បូង

**បណ្តាអ្នកអ្នកកាន់កាប់ដីតូចតាចបានដាំដើមឈើដោយប្រើប្រាស់កូនឈើ ថវិកា ជីគីមី និងទទួលការណែនាំពីក្រុមហ៊ុនឯកជនដែលនឹងទិញផលិតផលពីកសិករទាំងនោះសំរាប់ផលិតជាម្សៅក្រដាស។** កិច្ចសហការនេះផ្គត់ផ្គង់វត្ថុធាតុដើមប្រហែល១០% នៃតំរូវការរបស់រោងចក្រ ហើយមានតម្លៃថ្លៃជាងឈើដែលមកពីប្រភពឯទៀត ក៏ប៉ុន្តែវាជាប្រភពវត្ថុធាតុដើមដែលមិនអាចរកបានពីប្រភពផ្សេងទៀតនិងថែមទាំងជួយឱ្យខ្សែចង្វាក់ផលិតកម្មនៃរោងចក្រដំណើរការពេញបន្ទុកប្រកបដោយប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់។ គំរោងការណ៍នេះ បានធ្វើឱ្យមានការកើនឡើងនូវប្រាក់ចំណូលប្រចាំគ្រួសារយ៉ាងសំបើម ប៉ុន្តែនៅតែមិនអាចរុញជីវភាពគ្រួសារនៃអ្នកកាន់កាប់ដីតូចតាចទាំងនោះឱ្យរួចផុតពីភាពក្រីក្របានដដែល (Mayeers and Vermuelen, 2002)។

# ៣. សង្គមព្រៃឈើ

## ៣.១ ការគ្រប់គ្រងព្រៃឈើដោយមានកិច្ចសហការ

ការគ្រប់គ្រងព្រៃឈើដោយមានការចូលរួម **ចាប់ផ្តើមមានពន្លកឡើងបន្ទាប់ពីគោលនយោបាយវិស័យព្រៃឈើបានតំរង់ទីសទៅរកការអភិរក្ស** និងបំពេញតំរូវការរបស់ប្រជាជនដែលរស់នៅដោយពឹងពាក់លើព្រៃឈើ ។ វិធីសាស្ត្រនេះទាមទារឱ្យមានការគ្រប់គ្រងព្រៃឈើតាមរយៈភាពជាដៃគូររវាងវិស័យព្រៃឈើនិងសហគមន៍ ដែលការណ៍នេះ**ទាមទារជាចាំបាច់ឱ្យមានការផ្លាស់ប្តូរនូវឥរិយាបទ** ទាំងសហគមន៍និងនាយកដ្ឋានព្រៃឈើ **និងទាមទារឱ្យមានការប្រគល់ទៅឱ្យសហគមន៍នូវការទទួលខុសត្រូវនានា** ។ សំរាប់ការផ្លាស់ប្តូរក្នុងសហគមន៍ មានរួមបញ្ចូលទាំងតម្រូវការឱ្យមានអង្គការចាត់តាំងច្បាស់លាស់ ការដោះស្រាយនូវជម្លោះ និងកិច្ចសហការធ្វើការងារជាមួយនឹងមន្ត្រីរុក្ខា ហើយសំរាប់មន្ត្រីរុក្ខាវិញ ទាមទារឱ្យមានការទំនាក់ទំនងជាមួយនឹងប្រជាជន និង បែងចែកអំណាចក្នុងការធ្វើសេចក្តីសំរេច ចិត្ត ។

ប្រទេសឥណ្ឌា

ស្របពេលនឹងការធ្វើនយោបាយវិមជ្ឈការ ការគ្រប់គ្រងព្រៃឈើដោយមានកិច្ចសហការត្រូវបានអនុវត្តន៍តាមរយៈគណកម្មការព្រៃឈើភូមិដោយធ្វើសមាហរណកម្មវិស័យព្រៃឈើទៅក្នុងផែនការអភិវឌ្ឍន៍រួម ។ ផ្ទៃដីប្រមាណ ១៤ លានហិកតា ថិតនៅក្រោមការគ្រប់គ្រងតាមរបៀបការគ្រប់គ្រងព្រៃឈើដោយមានកិច្ចសហការ ហើយនៅតំបន់ជាច្រើនគេពិនិត្យឃើញមានការកើនឡើងនូវគំរបព្រៃ ដែលនេះជាសញ្ញានៃការកើនឡើងនូវប្រាក់ចំណូលរបស់ប្រជាជនមូលដ្ឋាន ។ ក៏ប៉ុន្តែ ទន្ទឹមពេលនឹងទំនាក់ទំនងរវាងមន្ត្រីរុក្ខានិងសហគមន៍មូលដ្ឋានកាន់តែមានភាពល្អប្រសើរ **គេពុំទាន់ឃើញមានការផ្ទេរអំណាចទៅឱ្យអង្គការចាត់តាំងនៅថ្នាក់ភូមិនៅឡើយទេ** ហេតុការណ៍នេះនាំទៅដល់ការទាមទារឱ្យមានការពង្រឹងការគ្រប់គ្រងព្រៃឈើដោយមានកិច្ចសហការតាមរយៈការដាក់បញ្ចូលនូវទស្សនទាននៃការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន ដែលធ្វើឱ្យមានការកើនឡើងនូវភាពស្របច្បាប់និងអំណាចរបស់សហគមន៍មូលដ្ឋានលើសពីនោះធានានូវជីវភាពនៃប្រជាជនជនបទក៏ដូចជាជោគជ័យក្នុងការស្តារដីព្រៃឈើឡើងវិញ (Khare et al., 2000, Biswas, 2003) ។

## ៣.២ សហគមន៍ព្រៃឈើ

រាប់សតវត្សមកហើយអ្នកភូមិនានានៅជុំវិញពិភពលោកបានប្រើប្រាស់និងគ្រប់គ្រងព្រៃឈើដោយចាត់ទុកជាប្រភពធនធានរួមរួមរបស់ភូមិ ។ **ដូច្នេះទស្សនៈអំពីសហគមន៍ព្រៃឈើមិនមែនថ្មីទេ ប៉ុន្តែទើបតែលេចចេញនាពេលថ្មីៗនេះដោយសារការទទួលស្គាល់ថាជាជំរើសដ៏ប្រសើរមួយក្នុងការគ្រប់គ្រងព្រៃឈើរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម នៅ**

ពេលដែលឧស្សាហកម្មព្រៃឈើជាទ្រង់ទ្រាយធំទទួលបរាជ័យ ។ ដោយមានការរួមចំណែកទទួលខុសត្រូវក្នុងការគ្រប់គ្រងព្រៃឈើពីសំណាក់ប្រជាជនមូលដ្ឋាន តួនាទីរបស់មន្ត្រីព្រៃឈើ បានងាកចេញពីទំលាប់ជា"ប៉ូលីស"ក្នុងវិស័យព្រៃឈើ ។

សហគមន៍ព្រៃឈើបានជួយឱ្យសហគមន៍មូលដ្ឋានមានសិទ្ធិអំណាច និងមានការទទួលខុសត្រូវក្នុងការប្រើប្រាស់ និងគ្រប់គ្រងព្រៃឈើនៅក្នុងតំបន់ដើម្បីផលប្រយោជន៍របស់ខ្លួន ។ ក៏ប៉ុន្តែ នៅពេលដែលសហគមន៍រៀបចំផែនការគ្រប់គ្រងព្រៃឈើដោយផ្អែកលើតំរូវការរបស់ខ្លួន ជានិច្ចកាលតែងតែមានតំរូវការឱ្យមានការយល់ព្រមពីនាយកដ្ឋានព្រៃឈើ ដែលធ្វើឱ្យមន្ត្រីព្រៃឈើមានឥទ្ធិពលធំធេងទៅលើផែនការគ្រប់គ្រងព្រៃឈើនោះ ។ ដោយសារមានភាពតឹងតែងដែលធ្លាប់បានជួបប្រទះកន្លងមក នោះទាមទារឱ្យមានការសើរើពិនិត្យឡើងវិញនូវការគាំទ្រពីស្ថាប័នដែលពាក់ព័ន្ធ ។

## ប្រទេសនេប៉ាល់

ផ្ទៃដីព្រៃឈើប្រមាណ ៦១% អាចមានលទ្ធភាពដាក់ឱ្យថិតនៅក្រោមការគ្រប់គ្រងរបស់សហគមន៍ព្រៃឈើ (Nelson and Tamrakar, cited in Dhital et al.,2001) ក៏ប៉ុន្តែដំណើការផ្តល់ការគ្រប់គ្រងដីព្រៃទាំងទៅឱ្យក្រុមប្រើប្រាស់ព្រៃឈើ (Forest User Groups)ហាក់ដូចជាមានការយឺតយ៉ាវ ហើយភាគច្រើនមិនមែនជាព្រៃផ្តល់ផល ឬជាដីព្រៃរេចរិល (Banerjee, 2001) ។ ភារកិច្ចរបស់មន្ត្រី (រុក្ខា) រដ្ឋាភិបាលត្រូវបានផ្លាស់ប្តូរ ហើយក្រុមប្រើប្រាស់ព្រៃឈើត្រូវបានលើកទឹកចិត្ត និង ជំរុញឱ្យមានសកម្មភាពកាន់តែខ្លាំងឡើងតាមរយៈការពូតផ្គុំគ្នារវាងចំណេះដឹងដែលមាននៅមូលដ្ឋាន ជាមួយនឹងចំណេះដឹងដែលជួយពីខាងក្រៅ (Dhital et al., 2001) ។

សហគមន៍ព្រៃឈើមិនទាន់បានអនុវត្តនៅក្នុងតំបន់ដែលសំបូរព្រៃឈើ និង ជាតំបន់ដែលមានដង់ស៊ីតេប្រជាជនតេរ៉ៃ (Terai) ខ្ពស់នៅឡើយទេ ហេតុការណ៍នេះបាននាំទៅដល់ការបង្កើត*ក្រុមសកម្មភាពសហគមន៍ព្រៃឈើតេរ៉ៃ* (Terai Community Forest Action Team) ។ ក្រុមនេះប្រៀបបាននឹងបណ្តាញការងារមួយដែលនឹងផ្តើមបង្កើតសហគមន៍ព្រៃឈើដែលសបញ្ជាក់ឱ្យឃើញថា នៅពេលដែលមានការប្រកួតប្រជែងនានាបញ្ហាដែលត្រូវប្រឈមមុខណាមួយនោះអាចនឹងត្រូវដោះស្រាយដោយងាយស្រួល(Shrestha,2001) ។

## ប្រទេសភីលីពីន

កម្មវិធីគ្រប់គ្រងព្រៃឈើដោយឈរលើមូលដ្ឋានសហគមន៍ បានធានានូវសុវត្ថិភាពក្នុងការកាន់កាប់ដីនៅតំបន់ណាដែលមានការគ្រប់គ្រងដោយប្រជាជនមូលដ្ឋាន និង ផ្តល់សិទ្ធិរុករកផលព្រៃឈើនៅក្នុងតំបន់ដែលបាន

ប្រគល់ឱ្យ ទៅឱ្យប្រជាជនដែលរស់នៅក្បែរនោះ ក្នុងពេលជាមួយគ្នាជំរុញឱ្យមានការវិនិយោគក្នុងវិស័យដាំឈើ កសិរុក្ខម្ម និង គំរោងនានានៅក្នុងសហគមន៍។ កម្មវិធីនេះគ្របដណ្តប់ទីតាំងប្រហែល ៥០ កន្លែង នៅលើផ្ទៃដីសរុបប្រមាណ ១៥០ 000 ហិកតា ហើយគេមានផែនការពង្រីក រហូតដល់ដំណាក់កាលមួយដែលតំរូវការផលិតផលឈើសំរាប់ប្រើប្រាស់ក្នុងស្រុក អាចនឹងត្រូវបានផ្គត់ផ្គង់ដោយសហគមន៍។ បញ្ហាដែលប្រឈមនាពេលថ្មីៗនេះគឺ**ភាពមិនទុកចិត្តគ្នារវាងមន្ត្រីរុក្ខានិងសហគមន៍** និរន្តរភាពនៃគំរោងដែលគាំទ្រថវិកាដោយអ្នកផ្តល់ជំនួយ និង កង្វះខាតនូវអ្នកផ្សព្វផ្សាយដែលមានបទពិសោធន៍ស្ម័គ្រចិត្តរស់នៅក្នុងតំបន់ដាច់ស្រយាល (Pasicolan,2003)។

### ប្រទេសឡាវ

ព្រៃឈើរបស់ភូមិ ត្រូវបានចាត់ទុកជាធាតុសំខាន់មួយនៃផែនការសកម្មភាពព្រៃឈើជាតិ ដែលផ្តោតការយកចិត្តទុកដាក់លើការផលិតឈើមូល ទោះបីជាគេដឹងថាផែនការនេះអាចសំរេចបានទាល់តែអ្នកភូមិយល់ច្បាស់អំពីផលប្រយោជន៍នៃកិច្ចខិតខំប្រឹងប្រែងក្នុងការងារសហគមន៍ព្រៃឈើ ផ្ទុយទៅវិញនៅពេលបច្ចុប្បន្នពួកអ្នកភូមិបាននិងកំពុងសស្រាក់សស្រាំបង្កើនការដាំដុះរុក្ខជាតិផ្តល់អនុផលព្រៃឈើនៅលើដីឯកជនរបស់ពួកគេទៅវិញ (Foppes and Ketphanh, 2001) ។

## ៣.៣ កិច្ចសហការគ្រប់គ្រងតំបន់ការពារ

ដោយមានការកើនឡើងនូវការទទួលស្គាល់តំលៃនៃការបាត់បង់ខាងផ្នែកសង្គម សេដ្ឋកិច្ច បរិស្ថាន និង វប្បធម៌របស់សហគមន៍មូលដ្ឋាន បណ្តាលមកពីការហាមឃាត់ការចូលទៅក្នុងតំបន់ប្រភពធនធានដោយសារតែការអភិរក្សបាននាំឱ្យមានការកើតឡើងនូវនិន្នាការនៃការគ្រប់គ្រងតំបន់ការពារដោយមានការចូលរួម។ សកម្មភាពនានាដែលបានធ្វើរួមគ្នារវាងអ្នកគ្រប់គ្រងតំបន់ការពារនិងសហគមន៍មូលដ្ឋាន បានច្របាច់បញ្ចូលគ្នានូវទំរង់នៃការអភិរក្សតាមបែបប្រពៃណី ហើយបានជួយកសាងនូវទំនុកចិត្តរវាងភាគីទាំងពីរ ។

### ប្រទេសឡាវ

តំបន់ការពារនៅប្រទេសឡាវត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៣ ជាមួយនឹងសេចក្តីប្រកាសដែលថាសហគមន៍មូលដ្ឋាននឹងត្រូវដាក់បញ្ចូលទៅក្នុងការគ្រប់គ្រងតំបន់ការពារទាំងនោះ ។នៅក្នុងភូមិជាច្រើន ប្រពៃណីនៃការគ្រប់គ្រងអភិរក្សធនធានព្រៃឈើត្រូវបានបន្តអនុវត្តន៍ដោយអ្នកភូមិដើម្បីការពារនូវប្រភពធនធានព្រៃឈើ សត្វព្រៃ និង ការពារព្រៃអារក្ស។ បច្ចុប្បន្ននេះប្រជាជនមូលដ្ឋានបានចូលរួមក្នុងការសិក្សាវាយតំលៃធនធាន

ជីវចំរុះ ។ កិច្ចការនេះបង្កើតឱ្យមានការជឿទុកចិត្តគ្នារវាងប្រជាជនមូលដ្ឋាន មន្ត្រីរដ្ឋាភិបាល និង អ្នកខាងក្រៅហើយបង្ហាញឱ្យឃើញផងដែរនូវការចាប់ផ្តើមនៃកិច្ចសហការក្នុងការគ្រប់គ្រងព្រៃឈើ ។ លើសពីនេះនៅក្នុងភូមិមួយចំនួន ក្រុមតាមដានមើលបទល្មើសព្រៃឈើត្រូវបានបង្កើតឡើងជាមួយនឹងមន្ត្រីនៃតំបន់ការពារ (Steinmetz, 2001) ។ **គំរូនៃកិច្ចសហការដែលបានប្រកាន់យកនៅក្នុងការងារគ្រប់គ្រងតំបន់ការពារនេះ នឹងបានជាគំរូល្អសំរាប់ការអនុវត្តន៍ក្នុងការគ្រប់គ្រងព្រៃដាំ ផងដែរ ។**

## ៤.កសិរុក្ខកម្ម

កសិរុក្ខកម្មរួមបញ្ចូលដោយការដាំរួមគ្នានៅលើដីធ្វើកសិកម្មនូវដំណាំកសិកម្មនិងដើមឈើមួយឬច្រើនប្រភេទ ។ ឧទាហរណ៍ មួយចនួនដូចជា ការដាំឈើនៅក្នុងចំការកសិកម្មពនេចរដើម្បីធានាលំនឹងប្រព័ន្ធកសិកម្ម ការដាំរុក្ខជាតិដែលផ្តល់អនុផលព្រៃឈើទៅក្នុងព្រៃសហគមន៍ ការដាំដំណាំកសិកម្មឆ្លាស់នឹងជួរកូនឈើក្នុងកំឡុងពេលបង្កើតចំការឈើ និងប្រព័ន្ធកសិកម្មច្រើនស្រទាប់នៅលើដីចំការតូចៗ ។ ប្រព័ន្ធរបៀបនេះបានពង្រាយកំលាំងពលកម្មពេញមួយឆ្នាំ និងបានផ្តល់ប្រាក់ចំណូលជាទៀងទាត់ ពីផលិតផលជាច្រើនប្រភេទដែលបេះប្រមូលនៅក្នុងរដូវកាលខុសៗគ្នា ។ ឧទាហរណ៍ផ្សេងទៀតរួមមានៈ

### ប្រទេសភូមា

របៀប *taungya* រួមមានការដាំដំណាំកសិកម្មនៅចន្លោះកូនឈើនៃចំការឈើម៉ៃសាក់ ដែលអនុញ្ញាតឱ្យកសិករ ដាំដំណាំកសិកម្មនៅក្នុងកំឡុងពេលបង្កើតចំការឈើម៉ៃសាក់ ដែលនេះជាការលើកទឹកចិត្តដល់កសិករឱ្យជួយការពារ ចំការកូនឈើ (Raintree, 2001) ។

### ប្រទេសភីលីពីន

*Ifugao woodlot* គឺជារបៀបដាំដើមឈើនៅតាមទីជំរាលដើម្បីការពារការហូរច្រោះដីចូលទៅក្នុងវាលស្រែ (ដែលនៅលើទីជំរាល) និង ដើម្បីផ្តល់ផលិតផលផ្សេងៗទៀតសំរាប់បំពេញតំរូវការរបស់កសិករ (Raintree, 2001) ។

### ប្រទេសឡាវ

នៅក្នុងខេត្តចំប៉ាសាក់ ចំការក្រវាញត្រូវបានដាំនៅក្រោមគំរបដើមឈើព្រៃខ្ពស់ៗដែលបន្សល់ទុកពីការកាប់រានព្រៃស្រោង ចំការរបៀបនេះផ្តល់នូវប្រាក់ចំណូលច្រើនគួរសមសំរាប់កសិករ (Foppes and Ketphanh, 2001) ។

ប្រទេសបង់ក្លាដេស

កសិករបានបង្កើតប្រព័ន្ធកសិកម្មសាំញ៉ាំមួយដែលមានដំណាំជាច្រើនស្រទាប់មានលទ្ធភាពផ្តល់នូវប្រាក់ចំណូលច្រើនគួរសមបើគិតនៅក្នុងមួយឯកត្តាដី។ បច្ចេកទេសនេះមានសារសំខាន់ណាស់ ជាពិសេសសំរាប់កសិករដែលមានដីចាំការតូច១ (Rahim and Islam, 2001)។

## ៥. ការដាំដើមឈើនៅក្នុងទីក្រុង

ដើមឈើនិងទីធ្លាដែលមានពតិបៃតង ធ្វើឱ្យទីក្រុងមានភាពមនោរម្យ ដោយសាររុក្ខជាតិទាំងនោះស្រូបយកនូវសារធាតុពុលនិងសំឡេង ធ្វើឱ្យមានភាពកាន់តែប្រសើរនូវអាកាសធាតុតាមតំបន់និមួយ១ ការពារនិងបង្កើនគុណភាពនៃធនធានធម្មជាតិដែលរួមមាន ដី ទឹក រុក្ខជាតិនិងសត្វព្រៃ និង រួមចំណែកដ៏សំខាន់ផ្តល់សោភ័ណភាពដល់ទីក្រុង។ លើសពីនេះ ដើមឈើផ្តល់វិភាគទានដោយផ្ទាល់ដល់តំរូវការផ្នែកចំណីអាហារ និង ថាមពល ដល់អ្នកក្រីក្រនៃទីក្រុង។

**កម្មវត្ថុនៃការដាំឈើនៅក្នុងទីក្រុងគឺ ដើម្បីទាញយកផលប្រយោជន៍ពីព្រៃឈើដែលមានសក្តានុពលក្នុងការរួមចំណែកកែលំអបរិស្ថាន សង្គម សេដ្ឋកិច្ច និង សុខមាលភាពនៃអ្នកទីក្រុង** (Kuchelmeister and Braatz, 2001)។ ការងារនេះរួមមានកាដាំដើមឈើដើម្បីការពារទីជំរាល ការពារលំនៅដ្ឋានសត្វព្រៃដែលមាននៅក្នុងទីក្រុង ផ្តល់កន្លែង សំរាកលំហែរកំសាន្ត ផ្តល់នូវទេសភាពធម្មជាតិ ជួយសំអាតកាកសំណល់នៅក្នុងទីក្រុង និង ជាប្រភពនៃវត្ថុធាតុដើមឈើមូលផងដែរ។

កន្លងមកការដាំឈើនៅក្នុងទីក្រុង បានផ្តោតការយកចិត្តទុដាក់ជាសំខាន់លើតំលៃខាងសោភ័ណភាពនៅក្នុងតំបន់សំខាន់១នៃទីក្រុង ក៏ប៉ុន្តែគេពិនិត្យឃើញមានការកើនឡើងនូវសំពាធទៅលើធនធានធម្មជាតិនៅតាមតំបន់ជាយក្រុង ដោយសារតែការកើនឡើងជាប្រចាំនូវអ្នកចំណូលថ្មី។ ដូច្នេះការដាំឈើនៅក្នុងទីក្រុង មានលទ្ធភាពរួមចំណែកអភិវឌ្ឍន៍និងបំពេញតំរូវការនៃអ្នកទីក្រុង ហើយនៅចុងបញ្ចប់ការងារនេះ**ត្រូវតែធ្វើសមាហរណកម្មចូលទៅក្នុងផែនការអភិវឌ្ឍន៍និងផែនការប្រើប្រាស់ដីរបស់ទីក្រុងផងដែរ**។

ឧទាហរណ៍ជាទូទៅនៃការងារដាំដើមឈើនៅក្នុងទីក្រុងរួមមាន:

- ការដាំ**ឈើហូបផ្លែ**នៅក្នុងដីឡូតិ៍
- ការដាំដើមឈើនៅតាមបណ្តោយដងផ្លូវសំរាប់ទាញយកផលជា**ឈើមូល** (នៅប្រទេសចិន និងម៉ាឡេស៊ី)
- ការដាំដើមឈើនៅតាមបណ្តោយដងផ្លូវសំរាប់**កាត់បន្ថយនូវការបំពុលបរិស្ថាន** (ប្រទេសថៃ)

**រដ្ឋបាល់ទីម័រ សហរដ្ឋអាមេរិក**

*គំរោងសាកល្បងប្រភពធនធាននៅក្នុងទីក្រុង***អនុវត្តនូវគោលការណ៍សហគមន៍ព្រៃឈើនៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យជីវិតនៅទីក្រុងមានភាពស្រស់បំព្រង តាមរយៈការស្តារ និង កែលំអបរិស្ថាន។** កម្មវិធីសហគមន៍ព្រៃឈើរដ្ឋបាល់ទីម័រ ធ្វើប្រតិបត្តិការតាមរយៈសមាគមន៍សហគមន៍ព្រៃឈើនៃអ្នកទីក្រុងដែលធ្វើសកម្មភាពក្នុងកំរិតតូចៗ ដើម្បីដោះស្រាយតំរូវការនៅមូលដ្ឋាននិងផ្តល់ផលប្រយោជន៍ដល់អ្នកស្រុកផងដែរ។ ដោយផ្តោតការយកចិត្តទុកដាក់ចំពោះតំបន់ដីវាល ផ្លូវថ្នល់ និង សួនច្បារ កម្មវិធីនេះទាមទារឱ្យមាននូវយុទ្ធសាស្ត្រជាទូទៅមួយដើម្បីដោះស្រាយគ្រប់បញ្ហារបស់សហគមន៍ ដែលរួមមានទាំងភាពក្រខ្សត់ អ្នកមានសិទ្ធិកាន់កាប់ផ្ទះសំបែងក្នុងកំរិតទាប ការជួបប្រទះនូវបញ្ហាក្នុងការសិក្សាអប់រំ និង រូបភាពអវិជ្ជមាននានានៅក្នុងសហគមន៍។ សកម្មភាពនេះ បង្កើតឱ្យមានការគោរពគ្នាទៅវិញទៅមកក្នុងចំណោមអ្នកចូលរួមបណ្តុះឱ្យមានគំនិតសមូហភាព និង បង្កើនតំលៃទ្រព្យសម្បត្តិតាមរយៈការបង្កើនភាពទាក់ទាញនៅក្នុងតំបន់។ ដើម្បីផ្តល់ការគាំទ្រឱ្យកាន់តែខ្លាំងក្លាដល់គំរោងការណ៍របស់សហគមន៍ អាជ្ញាធរក្រុងបានសើរើពិនិត្យ និង កែសំរួលឡើងវិញនូវវិធីសាស្ត្រគ្រប់គ្រងសួនឧទ្យានតាមបែបប្រពៃណី ហើយផ្តល់សេវាកម្មដល់ការសំរាកលំហែកំសាន្ត (Burch and Grove, 1993)។

## ៦. វិស័យព្រៃឈើសំរាប់ការប្រើប្រាស់ពិសេស

### ៦.១ យន្តការអភិវឌ្ឍន៍ស្អាត

យន្តការអភិវឌ្ឍន៍ស្អាត (CDM) បានបង្កើតឡើងក្រោមសន្ធិសញ្ញាក្រុងក្យូតូ (ប្រទេសជប៉ុន) ។ សន្ធិសញ្ញានេះអនុញ្ញាតឱ្យរដ្ឋាភិបាល ឬក្រុមហ៊ុនឯកជននៃបណ្តាប្រទេសឧស្សាហកម្មធំៗ អនុវត្តគំរោងកាត់បន្ថយការបំភាយឧស្ម័នពុលនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ហើយត្រូវបានប្រកាសទទួលស្គាល់តាមរយៈការផ្តល់ឱ្យនូវ "វិញ្ញាបនប័ត្រនៃការកាត់បន្ថយការបំភាយឧស្ម័នពុល" ដោយប្រៀបធៀបទៅនឹងទិសដៅកាត់បន្ថយការបំភាយឧស្ម័នពុលថ្នាក់ជាតិរបស់គេ។ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍អាចទាញយកផលចំណេញតាមរយៈការនាំមកនូវបច្ចេកវិជ្ជា ប្រភពធនធានហិរញ្ញវត្ថុ ផលិតផលថាមពលប្រកបដោយនិរន្តរភាព ការបង្កើននូវប្រសិទ្ធិភាពការងារនិងការអភិរក្ស ការកាត់បន្ថយភាពក្រីក្រតាមរយៈប្រាក់ចំណូលដែលបានមកពីឱកាសធ្វើការងារ និងផលប្រយោជន៍ខាងបរិស្ថាននៅក្នុងតំបន់។

ក្នុងនាមជាអ្នកស្រូបយកជាតិកាបូន **សកម្មភាពនានានៃវិស័យព្រៃឈើ ដូចជាការដាំឈើ និងការស្តារព្រៃឈើឡើងវិញ អាចចាត់ទុកជាយន្តការអភិវឌ្ឍន៍ស្អាត**។ ដោយសារតែភាពមិនប្រាកដប្រជានៃតួនាទីវិស័យព្រៃឈើក្នុងការបំពេញកម្មវត្ថុនៃសន្ធិសញ្ញានៃការប្រែប្រួលធាតុអាកាស ទាមទារឱ្យមានការធ្វើសេចក្តីសំរេចអំពីសកម្មភាពនានាទាក់ទងនឹងវិស័យព្រៃឈើឡើងវិញ។ ដោយប្រត្យក្ស ប្រភេទព្រៃដាំដែលមានទំហំធំគឺជាឃ្លាំងស្តុកកាបូនដ៏មានប្រសិទ្ធិភាព ក៏ប៉ុន្តែព្រៃប្រភេទនេះអាចរំខានដល់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពព្រោះ គេមិនអាចទាញយកនូវផលិតផល និងសេវាកម្មជាច្រើនប្រភេទពីព្រៃឈើសំរាប់ការលើកកំពស់ការិតជីវភាពរបស់សហគមន៍មូលដ្ឋានបានទេ។ ផ្ទុយទៅវិញ សហគមន៍អាចចូលរួមយ៉ាងសកម្មជាមួយនឹងគំរោង CDM តាមរយៈការចងជាចង្កោម។ ការងារនេះទាមទារឱ្យមានភាគីទីបីដើម្បីជួយចងក្រងជាក្រុមនូវគំរោងតូចៗ ផ្តល់នូវសេវាកម្មខាងផ្នែករដ្ឋបាល និង រកដំណោះស្រាយចំពោះប្រតិបត្តិការដែលមានចំណាយខ្ពស់។ ដូច្នេះជាការសំខាន់ដែលថា លក្ខណៈវិនិច្ឆ័យនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពដែលអាចទទួលយកបាននៅមូលដ្ឋាន ត្រូវតែបង្កើតឡើងសំរាប់ជាមូលដ្ឋានក្នុងការវាយតម្លៃគំរោងសំណើនានា។

**ដោយសារពុំមានឧទាហរណ៍ជាក់ស្តែងស្តីអំពីគំរោងយន្តការអភិវឌ្ឍន៍ស្អាត បណ្តាបទពិសោធន៍ទាំងឡាយអាចទាញចេញពីសកម្មភាពនៃកិច្ចសហការអនុវត្តន៍នានា ទោះបីជាសកម្មភាពទាំងនេះមិនសមស្របនឹងទទួលថវិកាសំរាប់ការអភិវឌ្ឍន៍ស្អាតក៏ដោយ។**

### ប្រទេសប្រេស៊ីល

ការផលិតឈើថាមពលនិងធ្យូងក្នុងការិតនិរន្តរភាព នឹងជំនួសការប្រើប្រាស់ថាមពលដែលបានមកពីផូស៊ីល

នៅក្នុងឧស្សាហកម្មស្លដែក។ ចំការប្រេងខ្យល់ដែលមានទិន្នផលខ្ពស់ចំនួន ២៣ ១០០ ហិកតា នឹងត្រូវបាន ដាំដុះ ដើម្បីផលិតជាធ្យូង ដោយប្រើប្រាស់បច្ចេកវិជ្ជាផលិតធ្យូងទំនើបចុងក្រោយបំផុតដែលមាននៅក្នុងប្រទេស។ នៅពេលដែលចំការឈើពេញវ័យ វាមានលទ្ធភាពស្រូបយកឧស្ម័នកាបូនឌីអុកស៊ីតប្រមាណ ៥ លានតោន (UNEP /RISO, គ្មានឆ្នាំ) ។

## ប្រទេសម៉ាឡេស៊ី

គំរោងកាត់បន្ថយជាតិកាបូនដែលមានទ្រង់ទ្រាយធំ មានគោលដៅស្តារឡើងវិញនូវផ្ទៃដីព្រៃរេចរិលទំហំប្រមាណ ២៥ ០០០ ហិកតា តាមរយៈការដាំបញ្ចូលនូវប្រភេទឈើពាណិជ្ជកម្មនៃប្រភេទឈើក្នុងស្រុក។ គេបានធ្វើការប៉ាន់ប្រមាណថា គំរោងនេះនឹងស្រូបយកកាបូនប្រមាណ ៤,២៥ លានតោន ផ្តល់ទិន្នផលជាឈើអារជាង ៤ លានម៉ែត្រគូប ផ្តល់ការងារដល់មនុស្ស ២៣០ នាក់ ក្នុងមួយឆ្នាំ ក្នុងកំឡុងពេលនៃការដាំឈើ និងផ្តល់ឱកាសសំរាប់ការងារស្រាវជ្រាវ និងបណ្តុះបណ្តាលដល់និស្សិតជាច្រើននាក់ (Aukland *et al.*, 2002) ។

## ប្រទេសកូស្តារិកា

គឺជាប្រទេសកំពុងអភិវឌ្ឍន៍តំបូងគេបង្អស់ដែលបានចាប់ផ្តើមអនុវត្តនូវកម្មវិធីស្រូបយកកាបូនថ្នាក់ជាតិមួយ (១៩៩៧) ដោយបានជំរុញលើកទឹកចិត្តម្ចាស់ដីទាំងឡាយឱ្យប្រើប្រាស់ដីរបស់ខ្លួនសំរាប់វិស័យព្រៃឈើ ហើយរដ្ឋជាអ្នកបង់ប្រាក់ដោយផ្ទាល់ចំពោះសេវាកម្មខាងផ្នែកបរិស្ថាន ដែលបន្ទាប់មករដ្ឋលក់សេវាកម្មនេះទៅឱ្យពួកអ្នកវិនិយោគទុននានា (Aukland *et al.*, 2002) ។

## ប្រទេសមិកស៊ិក

ប្រទេសនេះបានធ្វើការសិក្សាស្រាវជ្រាវ និង រៀបចំប្រព័ន្ធនៃការធ្វើសមាហរណកម្មផែនការ រដ្ឋបាលនិងការតាមដាន ដើម្បីប្រមូលផ្តុំផលប្រយោជន៍នានាទាក់ទងនឹងកាបូនពីបណ្តាសកម្មភាពតូចៗជាច្រើន។ គំរោងដែលមានឈ្មោះថា Plan Vivo បានផ្តល់ប្រាក់កំចីសំរាប់លក់កាបូនដល់កសិករដើម្បីចំណាយក្នុងការបង្កើតប្រព័ន្ធកសិរុក្ខកម្ម ចំការឈើតូចៗ និងសកម្មភាពដាំដើមឈើនៅក្នុងសហគមន៍។ គំរោង Plan Vivo បាន និងកំពុងអនុវត្តន៍ផងដែរនៅក្នុងប្រទេសឥណ្ឌានិងមានផែនការពង្រីកទៅក្នុងប្រទេសម៉ូសំប៊ិក និង យូហ្គង់ដា ហើយត្រូវអភិវឌ្ឍន៍ ឱ្យទៅជាប្រព័ន្ធមួយដើម្បីធានានូវភាពដែលអាចទទួលយកបានពី CDM (Aukland *et al.*, 2002) ។